DHCS

MICHELLE BAASS
DIRECTOR

State of California—Health and Human Services Agency
# Department of Health Care Services

GAVIN NEWSOM
GOVERNOR

(Insert Date)

## ព័ត៌មានសំខាន់ៗអំពីធានារ៉ាប់រងសុខភាពរបស់អ្នក

ជូនចំពោះអ្នកទទួលផល៖

ដំណឹងល្អ! អ្នកអាចនឹងទទួលបានអត្ថប្រយោជន៍ថែទាំសុខភាពច្រើនបន្ថែមទៀតក្នុងពេល ឆាប់ៗ។ សេវា Restricted scope Medi-Cal របស់អ្នកអាចនឹងផ្លាស់ប្តូរទៅជាសេវា full scope Medi-Cal ។

ចាប់ផ្តើមពីថ្ងៃទី **1 ខែឧសភា ឆ្នាំ 2022 តទៅ**, Older Adult Expansion ថ្មីនេះនឹងផ្តល់សេវា full scope Medi-Cal ដល់មនុស្សពេញវ័យដែលមានអាយុចាប់ពី 50 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិដើម្បីទទួលបានសេវា Medi-Cal ។ មិនមានបញ្ហាចំពោះស្ថានភាពអន្តោប្រវេសន៍ របស់អ្នកនោះឡើយ។

**តើខ្ញុំនឹងដឹងថាខ្ញុំអាចទទួលបានអត្ថប្រយោជន៍ថែទាំសុខភាពបន្ថែមពីសេវា full scope Medi-Cal ដោយរបៀបណា?**
អ្នកនឹងទទួលបានលិខិតមួយច្បាប់ ផ្ញើតាមប្រៃសណីយ៍ នៅខែមេសា ឆ្នាំ 2022។ លិខិតនេះ នឹងប្រាប់អ្នកថាតើអ្នកអាចទទួលបានសេវា full scope Medi-Cal ដែរឬយ៉ាងណា។ វាក៏នឹងប្រាប់អ្នកផងដែរថាពេលណាអ្នកនឹងចាប់ផ្តើមទទួលបានអត្ថប្រយោជន៍បន្ថែមនោះ។

**តើខ្ញុំនឹងទទួលបានសេវាថែទាំសុខភាពបន្ថែមទៀតពីសេវា full scope Medi-Cal ដែរឬទេ?**
បាទ/ចាស។ សេវា Medi-Cal ផ្តល់ការថែទាំសុខភាពដោយឥតគិតថ្លៃ ឬមានតម្លៃទាបសម្រាប់ពលរដ្ឋដែលរស់នៅក្នុងរដ្ឋ California។ សេវា Full scope Medi-Cal គឺខុសគ្នាពីសេវា restricted scope Medi-Cal ដែលអ្នកទទួលបានក្នុងពេលនេះ។ សេវា Restricted scope Medi-Cal រ៉ាប់រងតែលើសេវាកម្មមួយចំនួនតែប៉ុណ្ណោះ។ សេវានេះ ពុំរ៉ាប់រងលើឱសថ និងការថែទាំបឋមនោះទេ។

សេវា Full scope Medi-Cal រ៉ាប់រងសេវាទាំងនេះ និងសេវាច្រើនបន្ថែមទៀត ដូចជា៖

- ការព្យាបាលការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង
- ការថែទាំធ្មេញ
- ការថែទាំករណីសង្គ្រោះបន្ទាន់
- ការធ្វើផែនការគ្រួសារ
- ការថែទាំជើង
- ជំនួយក្នុងការស្តាប់
- ការថែទាំវេជ្ជសាស្ត្រ

- ផ្តល់ថ្នាំព្យាបាលតាមការណែនាំរបស់វេជ្ជបណ្ឌិតរបស់អ្នក
- សម្ភារៈផ្គត់ផ្គង់វេជ្ជសាស្រ្ត
- ការថែទាំសុខភាពផ្លូវចិត្ត
- ការថែទាំដោយអ្នកថែទាំផ្ទាល់ខ្លួន និងសេវាកម្មផ្សេងទៀតដែលជួយមនុស្សឱ្យនៅក្រៅមណ្ឌលថែទាំ
- ការបញ្ជូនទៅកាន់អ្នកឯកទេស ប្រសិនបើចាំបាច់
- ធ្វើតេស្តតាមការណែនាំរបស់វេជ្ជបណ្ឌិតរបស់អ្នក
- ការដឹកជញ្ជូនទៅជួបគ្រូពេទ្យ និងទន្តពេទ្យ និងដើម្បីទទួលថ្នាំរបស់អ្នកនៅ ឱសថស្ថាន
- ការថែរក្សាភ្នែក (វ៉ែនតា)

ប្រសិនបើឥឡូវនេះអ្នកទទួលបានសេវា Medi-Cal ទាក់ទងនឹងការមានផ្ទៃពោះ គឺអ្នកមាន សេវាវេជ្ជសាស្រ្តចាំបាច់ទាំងអស់ ដែលសេវា Medi-Cal រ៉ាប់រង។

អ្នកអាចស្វែងយល់បន្ថែមអំពីសេវា Medi-Cal នៅក្នុង Frequently Asked Questions (FAQ) ដែលភ្ជាប់មកជាមួយលិខិតនេះ។

**តើខ្ញុំនឹងទទួលបានសេវាថែទាំសុខភាពដោយរបៀបណា?**
មនុស្សភាគច្រើនដែលទទួលបានសេវា full scope Medi-Cal នឹងទទួលបានសេវាថែទាំ សុខភាពផ្សេងៗតាមរយៈគម្រោង Medi-Cal Managed Care Plan ។ គម្រោង Medi-Cal Managed Care Plan គឺជាគម្រោងសុខភាពមួយ។ គម្រោងនេះ ធ្វើការជាមួយវេជ្ជបណ្ឌិត មន្ទីរពេទ្យ ឱសថស្ថាន និងអ្នកផ្តល់សេវាថែទាំសុខភាពផ្សេងទៀតនៅក្នុងតំបន់សេវាកម្មរបស់ គម្រោង។ ពួកគេនឹងផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

នៅពេលដែលអ្នកចូលរួមក្នុងគម្រោង Medi-Cal Managed Care Plan អ្នកនៅតែអាចទទួលបានសេវាថែទាំសុខភាពមួយចំនួន តាមរយៈកម្មវិធី Fee-For-Service (regular) Medi-Cal។ សេវាទាំងនេះរួមមាន ឱសថស្ថាន ការព្យាបាល substance use disorder និងសេវាទន្តសាស្រ្ត។

ជម្រើសសម្រាប់គម្រោង Medi-Cal Managed Care health plan  របស់អ្នក គឺអាស្រ័យតាមខោនធីដែលអ្នករស់នៅ។ ខោនធីខ្លះមានគម្រោងមួយ ខោនធីខ្លះមានគម្រោងច្រើនជាងមួយ ដើម្បីជ្រើសរើស។ យើងនឹងផ្ញើសំបុត្រមួយដែលមានជម្រើសគម្រោងរបស់អ្នក ទៅកាន់អ្នកតាមប្រៃសណីយ៍។ ដើម្បីស្វែងយល់បន្ថែមអំពីជម្រើស Health Care Options របស់អ្នក៖

- **តាមទូរសព្ទ៖** សូមហៅទូរសព្ទមកកាន់លេខ **1-800-430-4263** ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ម៉ោង 8 ព្រឹក ដល់ម៉ោង 6 ល្ងាច។ អ្នកប្រើប្រាស់ TDD/TYY សូមហៅទូរសព្ទមកកាន់ លេខ 1-800-430-7077។ ការហៅទូរសព្ទនេះ ពុំគិតថ្លៃនោះទេ។
- **តាមអនឡាញ៖** សូមចូលទៅតំណភ្ជាប់ https://www.healthcareoptions.dhcs.ca.gov/.

**តើខ្ញុំនឹងទទួលបានសេវាថែទាំសុខភាពដោយរបៀបណា ប្រសិនបើខ្ញុំមានសេវា Medi-Cal ជាមួយនឹង Share of Cost (SOC)?**

ប្រសិនបើឥឡូវនេះអ្នកមាន SOC អ្នកនឹងទទួលបានសេវា full scope Medi-Cal ជាមួយនឹង SOC។ ប្រសិនបើអ្នកមាន SOC អ្នកនឹងទទួលបានសេវាថែទាំសុខភាពផ្សេងៗរបស់អ្នកតាមរយៈគម្រោង Fee-For-Service (regular) Medi-Cal។ អ្នកនឹងមិនចាំបាច់ជ្រើសរើស គម្រោង Medi-Cal Managed Care Plan មួយនោះឡើយ។

**តើខ្ញុំគួររក្សាកាត Medi-Cal Benefits Identification Card (BIC) របស់ខ្ញុំដែរឬទេ?**
បាទ/ចាស។ អ្នកគួរតែរក្សាកាត BIC របស់អ្នក។ វាជាកាតប្លាស្ទិកដែលមានរូបផ្កាផ្ទុំបភីពណ៌ទឹកក្រូច ឬ ការរចនាពណ៌ខៀវ និងស។ អ្នកនឹងត្រូវការវាជាចាំបាច់នៅពេលអ្នកទទួលបានសេវា full scope Medi-Cal។ សូមហៅទូរសព្ទទៅកាន់ការិយាល័យប្រចាំខោនធីរបស់អ្នក ប្រសិនបើអ្នកត្រូវការកាត BIC ថ្មី។

ត្រូវតែយកកាត BIC របស់អ្នកទៅជាមួយ នៅពេលទៅជួបវេជ្ជបណ្ឌិតរបស់អ្នក និងទៅពិនិត្យសុខភាព និង ពិនិត្យមាត់ធ្មេញផ្សេងទៀត។ ពេលអ្នកស្ថិតក្នុងគម្រោង Medi-Cal Managed Care Plan អ្នកនឹងទទួលបានកាតមួយពីគម្រោងថ្មីរបស់អ្នក។ អ្នកនឹងចាំបាច់ត្រូវបង្ហាញកាត ទាំងពីរនៅពេលអ្នកទៅជួបវេជ្ជបណ្ឌិតរបស់អ្នក ពេទ្យធ្មេញ ឱសថស្ថាន និងអ្នកផ្តល់សេវា វេជ្ជសាស្ត្រផ្សេងទៀត។

**តើខ្ញុំចាំបាច់ត្រូវបំពេញពាក្យសុំសេវា Medi-Cal ថ្មីដែរឬទេ?**
ទេ។ អ្នកមានសេវា restricted scope Medi-Cal រួចហើយ ដូច្នេះអ្នកមិនចាំបាច់ត្រូវបំពេញពាក្យស្នើសុំ សេវា full scope Medi-Cal ថ្មីនោះឡើយ។

ប្រសិនបើអ្នកទទួលបានកញ្ចប់មួយនៅក្នុងសំបុត្រប្រៃសណីយ៍ដើម្បីបន្តសេវា Medi-Cal របស់អ្នក អ្នកត្រូវ បំពេញ ហើយបញ្ជូនវាត្រឡប់មកវិញ។ អ្នកអាចទូរសព្ទទៅការិយាល័យប្រចាំ ខោនធីរបស់អ្នកឱ្យជួយ។

**តើខ្ញុំទទួលបានឯកសារជាទម្រង់ផ្សេងដោយរបៀបណា?**
អ្នកអាចស្នើសុំព័ត៌មានជាលាយលក្ខណ៍អក្សរទាំងអស់អំពីអត្ថប្រយោជន៍សេវា Medi-Cal របស់អ្នកតាមទម្រង់ផ្សេង។ ទម្រង់អាចជាអក្សរសម្រាប់មនុស្សពិការភ្នែក (Braille) អក្សរបោះពុម្ពធំៗ CD សម្លេង ឬទិន្នន័យ ឬជាទម្រង់ផ្សេងទៀតដើម្បីជួយឱ្យអ្នកយល់ និងអានអក្សរ ឬបំពេញកញ្ចប់ព័ត៌មានរបស់អ្នក។ ដើម្បីសុំព័ត៌មាននេះ អ្នកអាច៖

- ចូលទៅតំណភ្ជាប់ https://afs.dhcs.ca.gov.
  ធ្វើតាមការណែនាំដើម្បីជ្រើសរើសទម្រង់ផ្សេងៗគ្នា។
- សូមហៅទូរសព្ទមកកាន់លេខ **1-833-284-0040** (California Relay 711), ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច លើកលែងតែថ្ងៃបុណ្យជាតិ។ ការហៅទូរសព្ទនេះ ពុំគិតថ្លៃនោះទេ។
- ទាក់ទងទៅកាន់ការិយាល័យប្រចាំខោនធីក្នុងមូលដ្ឋានរបស់អ្នក។

**ចុះបើខ្ញុំត្រូវការជំនួយជាភាសាផ្សេង?**

ប្រសិនបើអ្នកត្រូវការជំនួយជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស សូមអានបញ្ជីលេខទូរសព្ទ សម្រាប់សេវាកម្មជំនួយផ្នែកភាសាដោយឥតគិតថ្លៃដែលភ្ជាប់មកជាមួយលិខិតនេះ។ អ្នកក៏អាចទទួលបានអ្នកបកប្រែដើម្បីជួយអ្នកអានសំបុត្រនេះផងដែរ។

## តើខ្ញុំអាចស្វែងយល់បន្ថែម ឬទទួលបានជំនួយដោយរបៀបណា?

**ដើម្បីស្វែងយល់បន្ថែមអំពី Medi-Cal៖**
សូមហៅទូរសព្ទទៅកាន់ខ្សែទូរសព្ទជំនួយរបស់ Department of Health Care Services (DHCS) Medi-Cal តាមលេខ **1-800-541-5555** ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច លើកលែងតែថ្ងៃ បុណ្យជាតិ។ ការហៅទូរសព្ទនេះពុំគិតថ្លៃនោះទេ។

**ដើម្បីស្វែងយល់បន្ថែមអំពីគម្រោង Medi-Cal Managed Care Plans៖**
សូមហៅទូរសព្ទទៅកាន់ Health Care Options តាមរយៈលេខ **1-800-430-4263** ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ម៉ោង 8 ព្រឹក ដល់ម៉ោង 6 ល្ងាច។ អ្នកប្រើប្រាស់ TDD/TYY សូមហៅមកកាន់ លេខ 1-800-430-7077។ ការហៅទូរសព្ទនេះ ពុំគិតថ្លៃនោះទេ។

ឬ ចូលទៅកាន់គេហទំព័ររបស់ DHCS តាមរយៈតំណភ្ជាប់ https://bit.ly/older-adult-expansion.

**សម្រាប់សំណួរផ្សេងៗអំពីអន្តោប្រវេសន៍ និងកម្មវិធី Medi-Cal៖**
Department of Health Care Services (DHCS) មិនអាចឆ្លើយសំណួរអំពីអន្តោប្រវេសន៍ ឬ “public charge” បានទេ។

California Department of Social Services (CDSS) ផ្តល់មូលនិធិដល់អង្គការមិនរកប្រាក់ កម្រៃ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីផ្តល់សេវានានាដល់ជនអន្តោប្រវេសន៍ដែលរស់នៅរដ្ឋ California។ មានបញ្ជីឈ្មោះអង្គការទាំងនេះ តាមតំណភ្ជាប់ https://bit.ly/immigration-service-contractors.

សម្រាប់ព័ត៌មានអំពីអន្តោប្រវេសន៍និងធនធាននានា សូមចូលទៅកាន់ California’s Immigrant Guide តាមតំណភ្ជាប់ https://immigrantguide.ca.gov/.

ដើម្បីស្វែងយល់អំពី public charge សូមចូលទៅកាន់មគ្គុទ្ទេសក៍របស់ California Health and Human Services Agency Public Charge តាមតំណភ្ជាប់ https://bit.ly/calhhs-public-charge-guide.

សូមអរគុណ

Department of Health Care Services